# ការចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សាសម្រាប់ឆ្នាំ2024



ការចាប់ផ្តើមចូលរៀននៅសាលា គឺជាពេលវេលាដ៏រំភើបមួយសម្រាប់កូនៗ ឪពុកម្តាយ និងអ្នកថែទាំ។ ពួកយើងចង់ជួយឱ្យដំណើរការចុះឈ្មោះចូលរៀនកាន់តែងាយស្រួល តាមដែលអាចធ្វើទៅបានសម្រាប់អ្នក។

នៅរដ្ឋវិចថូរៀ កូនរបស់អ្នកមានសិទ្ធិចូលរៀននៅសាលាជិតខាងដែលបានកំណត់ (`សាលារៀនក្នុងតំបន់´ របស់អ្នក) ក្រោម *ច្បាប់កំណែទម្រង់ការអប់រំ និងបណ្តុះបណ្តាល ឆ្នាំ2006*។

អ្នកក៏អាចដាក់ពាក្យសុំចូលរៀននៅសាលារៀនដែលមិនមែនជាសាលាក្នុងតំបន់របស់អ្នកបានដែរ។ សាលារៀននឹងពិចារណាលើពាក្យសុំរបស់អ្នកស្របតាមគោលការណ៍ទទួលសិស្សចូលរៀន។ សម្រាប់ព័ត៌មានបន្ថែមអំពីគោលការណ៍ទទួលសិស្សចូលរៀន សូមចូលទៅកាន់គេហទំព័រ ការចុះឈ្មោះចូលរៀននៅសាលា។

## តារាងពេលវេលាថ្មីនៅទូទាំងរដ្ឋ សម្រាប់ថ្នាក់មូលដ្ឋាន (ថ្នាក់ត្រៀម។)

ឆ្នាំដំបូងនៃសាលាបឋមសិក្សាត្រូវបានគេហៅថាថ្នាក់មូលដ្ឋាន ឬថ្នាក់ត្រៀម។ យើងបានចេញផ្សាយតារាងពេលវេលាចុះឈ្មោះថ្នាក់មូលដ្ឋានមួយ សម្រាប់សាលាបឋមសិក្សារដ្ឋក្នុងរដ្ឋវិចថូរៀទាំងអស់ដើម្បីអនុវត្តតាម (សូមមើលទំព័រទី 3)។ តារាងពេលវេលាមានគោលបំណងជួយអ្នកឱ្យយល់ដឹងអំពីពេលវេលា និងពីរបៀបចុះឈ្មោះកូនរបស់អ្នកចូលរៀនក្នុងថ្នាក់មូលដ្ឋាន សម្រាប់ឆ្នាំសិក្សា2024។

## តើពេលណាខ្ញុំគួរចុះឈ្មោះកូនៗរបស់ខ្ញុំឱ្យចូលរៀននៅសាលាបឋមសិក្សា?

កូនរបស់អ្នកត្រូវមានអាយុ5ឆ្នាំត្រឹមថ្ងៃទី30ខែមេសា ក្នុងឆ្នាំដែលពួកគេចាប់ផ្តើមចូលរៀន។

ការចូលរៀនគឺជាកាតព្វកិច្ចសម្រាប់កុមារដែលមានអាយុ6ឆ្នាំ។

ដើម្បីចុះឈ្មោះកូនរបស់អ្នកនៅសាលាបឋមសិក្សារដ្ឋវិចថូរៀ សម្រាប់ឆ្នាំសិក្សា2024 សូមដាក់ពាក្យសុំចុះឈ្មោះចូលរៀននៅសាលាត្រឹមថ្ងៃទី28 ខែកក្កដា ឆ្នាំ2023។

## តើខ្ញុំអាចចុះឈ្មោះកូនរបស់ខ្ញុំក្នុងឆ្នាំដំបូងរបស់ពួកគេនៅសាលាបឋមសិក្សាដោយរបៀបណា?

អនុវត្តតាមជំហានទាំងនេះ ដើម្បីចុះឈ្មោះកូនរបស់អ្នកក្នុងឆ្នាំដំបូងរបស់ពួកគេនៅសាលាបឋមសិក្សា

1. ស្វែងរកសាលារៀនក្នុងតំបន់របស់អ្នកនៅលើគេហទំព័រ Find my School (ស្វែងរកសាលារបស់ខ្ញុំ) (សូមមើលខាងក្រោម)។
2. ទាក់ទងសាលាបឋមសិក្សារបស់រដ្ឋាភិបាល ដើម្បីណាត់សុំទស្សនកិច្ចសាលា ឬដើម្បីស្វែងយល់បន្ថែមអំពីសាលា និងដំណើរការចុះឈ្មោះចូលរៀន។
3. ទាញយកកញ្ចប់ព័ត៌មានអំពីការចុះឈ្មោះចូលរៀនថ្នាក់មូលដ្ឋាន (ថ្នាក់ត្រៀម)ចេញពី ការចុះឈ្មោះចូលរៀនថ្នាក់មូលដ្ឋាន (ថ្នាក់ត្រៀម) (មានចាប់ពីថ្ងៃទី24 ខែមេសា ឆ្នាំ2023)។
4. ដាក់ពាក្យចុះឈ្មោះចូលរៀនថ្នាក់មូលដ្ឋាន **ត្រឹមថ្ងៃសុក្រ ទី28 ខែកក្កដា ឆ្នាំ2023**។
5. អ្នកនឹងត្រូវបានជូនដំណឹងអំពីលទ្ធផលនៃការដាក់ពាក្យសុំរបស់អ្នក **ត្រឹមថ្ងៃសុក្រ ទី11 ខែសីហា ឆ្នាំ2023**។ ប្រសិនបើអ្នកទទួលបានការយល់ព្រមឱ្យចូលរៀន អ្នកគួរតែទទួលយកការផ្តល់នេះ **ត្រឹមថ្ងៃសុក្រ ទី24 ខែសីហា ឆ្នាំ2023**។
6. ចូលរួមនៅក្នុងវគ្គផ្តល់ព័ត៌មានអំពីការចុះឈ្មោះ និងការផ្ទេរអន្តរកាល **ក្នុងអំឡុងត្រីមាសទី4 ឆ្នាំ២2023**។
7. កូនរបស់អ្នកនឹងចាប់ផ្តើមថ្នាក់មូលដ្ឋាន **ចាប់ពីថ្ងៃអង្គារ ទី30 ខែមករា ឆ្នាំ2024**។

## តើខ្ញុំស្វែងរកសាលារៀនក្នុងតំបន់របស់ខ្ញុំដោយរបៀបណា?

អ្នកអាចស្វែងរកសាលារៀនក្នុងតំបន់របស់អ្នកនៅលើគេហទំព័រ Find My School ដោយធ្វើតាមជំហានខាងក្រោម៖

1. បញ្ចូលពាក្យ findmyschool.vic.gov.au ទៅក្នុងកម្មវិធីរុករកក្នុងអ៊ីនធើណិតរបស់អ្នក។
2. បញ្ចូលអាសយដ្ឋានអចិន្ត្រៃយ៍របស់អ្នកនៅក្រោមពាក្យ "បញ្ចូលអាសយដ្ឋានរបស់អ្នកដើម្បីចាប់ផ្តើម"។
3. ជ្រើសរើសឆ្នាំ2024 ក្រោមពាក្យ "ឆ្នាំចុះឈ្មោះ"។ **កំណត់ចំណាំ៖** តំបន់សាលារៀន ឆ្នាំ2024 នឹងមានដាក់បញ្ចូលនៅចុងត្រីមាសទី 1 ឆ្នាំ 2023។
4. ជ្រើសរើសបឋមសិក្សានៅក្រោមពាក្យ 'ប្រភេទសាលារៀន'។

បន្ទាប់មកផែនទីនឹងបង្ហាញអាសយដ្ឋានរបស់អ្នក សាលារៀនក្នុងតំបន់របស់អ្នក ហើយនៅផ្នែកខាងឆ្វេងនឹងបង្ហាញពីព័ត៌មានទំនាក់ទំនងលម្អិតរបស់សាលារៀន។ ប្រសិនបើអ្នករំកិលចុះក្រោមទៀត វាក៏នឹងបង្ហាញអ្នកនូវសាលារៀនចំនួនប្រាំដែលនៅជិតអាសយដ្ឋានរបស់អ្នកបំផុត។

អ្នកក៏អាចស្វែងរកតាមឈ្មោះសាលារៀនផងដែរនៅក្រោមពាក្យ ' ស្វែងរកសាលារៀន'។

## តើកូនរបស់ខ្ញុំអាចដាក់ពាក្យសុំចូលរៀនសាលាបឋមសិក្សារបស់រដ្ឋដែល មិនមែនជាសាលារៀនក្នុងតំបន់របស់ពួកយើងបានដែរឬទេ?

បាទ/ចាស អ្នកអាចដាក់ពាក្យសុំចូលសាលារៀនក្រៅពីសាលារៀនក្នុងតំបន់របស់អ្នកបាន។ សាលារៀននឹងពិចារណាលើពាក្យសុំរបស់អ្នកស្របតាមគោលការណ៍ទទួលសិស្សចូលរៀន និងកន្លែងទំនេរ។ អ្នកអាចស្វែងរកព័ត៌មាននៅលើគេហទំព័រ អំពីរបៀបដាក់ពាក្យសុំដែលត្រូវបានផ្តល់អាទិភាពការចុះឈ្មោះចូលរៀននៅសាលា។

## តើមានអ្វីកើតឡើងប្រសិនបើខ្ញុំទទួលបានសំបុត្រមួយ ដែលនិយាយថាពាក្យសុំចុះឈ្មោះរបស់ខ្ញុំមិនបានជោគជ័យ?

អ្នកគួរតែដាក់ពាក្យសុំចុះឈ្មោះចូលរៀនរបស់កូនអ្នកនៅសាលាផ្សេងទៀត។ កូនរបស់អ្នកត្រូវបានធានាឱ្យចូលរៀននៅសាលារៀនក្នុងតំបន់របស់ពួកគេ។ សាលារៀនក្នុងតំបន់របស់កូនអ្នកត្រូវបានកំណត់ដោយផ្អែកលើអាសយដ្ឋានរស់នៅអចិន្ត្រៃយ៍របស់ពួកគេ។ សូមចូលទៅកាន់ Find my School ដើម្បីកំណត់ទីតាំងសាលារៀនក្នុងតំបន់របស់កូនអ្នក។ គេហទំព័រការចុះឈ្មោះចូលរៀន ក៏អាចជួយអ្នកក្នុងការបញ្ជាក់ពីអាសយដ្ឋានរបស់កូនអ្នកសម្រាប់ការចុះឈ្មោះផងដែរ។

អ្នកក៏អាចធ្វើការតវ៉ាលើការសម្រេចចិត្តផងដែរ។ គេហទំព័រការចុះឈ្មោះចូលរៀនថ្នាក់មូលដ្ឋាន (ថ្នាក់ត្រៀម) មានព័ត៌មានអំពីដំណើរការដើម្បីប្ដឹងតវ៉ាអំពីលទ្ធផលនៃការដាក់ពាក្យសុំចូលរៀន។

## តើមានអ្វីកើតឡើងប្រសិនបើខ្ញុំខកខានចំពោះពេលវេលាចុះឈ្មោះ?

អ្នកអាចដាក់ពាក្យសុំចុះឈ្មោះកូនរបស់អ្នកចូលថ្នាក់មូលដ្ឋាន សម្រាប់ឆ្នាំសិក្សា2024 នៅពេលណាក៏បានដែរ ចាប់ពីត្រីមាសទី2 ឆ្នាំ2023។

ខណៈពេលដែលអ្នកត្រូវបានស្នើសុំឱ្យដាក់ពាក្យចុះឈ្មោះចូលរៀន ត្រឹមថ្ងៃសុក្រ ទី27 ខែកក្កដា ឆ្នាំ2023 ពាក្យស្នើសុំក្រោយកាលបរិច្ឆេទនេះនឹងនៅតែត្រូវបានទទួលយក ពីក្រុមគ្រួសារដែលខកខានក្នុងការចុះឈ្មោះ ដោយសារការផ្លាស់ប្តូរទីលំនៅ ឬទើបមករស់នៅក្នុងរដ្ឋវិចថូរៀថ្មីៗ។

សាលានឹងពិចារណាលើពាក្យស្នើរសុំរបស់អ្នក ស្របតាមគោលការណ៍ទទួលសិស្សចូលរៀនរបស់ក្រសួង។

## តើខ្ញុំអាចស្វែងរកព័ត៌មានបន្ថែមអំពីការចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សានៅឯណា?

អ្នកអាចសួរសាលាបឋមសិក្សាក្នុងតំបន់របស់អ្នក សម្រាប់ព័ត៌មានបន្ថែមអំពីដំណើរការចុះឈ្មោះចូលរៀនថ្នាក់មូលដ្ឋាន។

នៅដើមត្រីមាសទី2 ឆ្នាំ2023 អ្នកក៏អាចរកបានកញ្ចប់ព័ត៌មានអំពីដំណើរការចុះឈ្មោះចូលរៀនថ្នាក់មូលដ្ឋានផងដែរនៅលើគេហទំព័រ ការឈ្មោះចូលរៀនថ្នាក់មូលដ្ឋាន (ថ្នាក់ត្រៀម) នៃគេហទំព័រ ការចាប់ផ្តើមចូលរៀននៅសាលា។

ប្រសិនបើអ្នកត្រូវការជំនួយក្នុងការបកប្រែកញ្ចប់ព័ត៌មាន សូមនិយាយទៅកាន់សាលាបឋមសិក្សាក្នុងតំបន់របស់អ្នកដើម្បីសុំជំនួយ។

## តើខ្ញុំត្រូវទាក់ទងអ្នកណាដើម្បីសុំជំនួយ?

អ្នកសម្របសម្រួលការផ្ទេរអន្តរកាល មន្ត្រីចុះឈ្មោះ ឬនាយកសាលាបឋមសិក្សាដែលអ្នកចង់ដាក់ពាក្យសុំ អាចជួយអ្នកដើម្បីឆ្លើយតបនឹងសំណួរណាមួយដែលអ្នកចង់សួរ អំពីដំណើរការចុះឈ្មោះ។

## តំណភ្ជាប់ដែលមានប្រយោជន៍

សូមស្វែងរកតំណភ្ជាប់ដែលមានប្រយោជន៍មួយចំនួនខាងក្រោម ដែលអាចមានប្រយោជន៍សម្រាប់អ្នក នៅពេលដែលកូនរបស់អ្នកចាប់ផ្តើមចូលរៀននៅសាលាបឋមសិក្សានៅឆ្នាំ2024៖

ស្វែងរកសាលារៀនរបស់ខ្ញុំ – findmyschool.vic.gov.au

ព័ត៌មានអំពីតំបន់សាលារៀន – vic.gov.au/school-zones

ការចុះឈ្មោះចូលរៀនថ្នាក់មូលដ្ឋាន (ថ្នាក់ត្រៀម) – vic.gov.au/enrolling-foundation-prep

ការចុះឈ្មោះចូលរៀននៅសាលា – vic.gov.au/how-choose-school-and-enrol

ពិការភាព និងការអប់រំរួមបញ្ចូល – vic.gov.au/disability-and-inclusive-education

ទំនាក់ទំនងការិយាល័យប្រចាំតំបន់ភូមិភាគ – vic.gov.au/office-locations-department-education-and-training

# តារាងពេលវេលាសម្រាប់ឆ្នាំ2023-2024

| កាលបរិច្ឆេទ ឆ្នាំ2023 | សកម្មភាព |
|---|---|
| **ត្រីមាសទី2៖ ថ្ងៃចន្ទ ទី24 ខែមេសា ឆ្នាំ2023 - ថ្ងៃសុក្រ ទី23 ខែមិថុនា ឆ្នាំ2023** | |
| **ត្រីមាសទី1 និងទី2 ឆ្នាំ2023** | សាលាបឋមសិក្សារៀបចំដំណើរទស្សនកិច្ច រៀបចំវគ្គផ្តល់ព័ត៌មាន និងសកម្មភាពផ្សេងទៀតសម្រាប់ក្រុមគ្រួសារដែលស្វែងរកការចុះឈ្មោះចូលរៀនថ្នាក់មូលដ្ឋាន (ថ្នាក់ត្រៀម) សម្រាប់កូនរបស់ពួកគេក្នុងឆ្នាំ2024។ |
| **ត្រឹមដើមត្រីមាសទី2 ឆ្នាំ2023** | តំបន់សាលាសម្រាប់ឆ្នាំសិក្សា2024 ធ្វើការផ្សាយផ្ទាល់នៅលើគេហទំព័រ findmyschool.vic.gov.au<br>ឪពុកម្តាយ/អ្នកថែទាំ គួរតែចូលទៅកាន់គេហទំព័រ findmyschool.vic.gov.au ដើម្បីកំណត់ទីតាំងសាលារៀនរបស់ពួកគេសម្រាប់ឆ្នាំ2024។<br>កញ្ចប់ព័ត៌មានចុះឈ្មោះចូលរៀនសម្រាប់ឪពុកម្តាយ/អ្នកថែទាំ អាចទាញយកបានពី ការចុះឈ្មោះចូលរៀនថ្នាក់មូលដ្ឋាន (ថ្នាក់ត្រៀម)។ |
| **ចាប់ពីសប្តាហ៍ទី1 ត្រីមាសទី2 ឆ្នាំ2023** | សាលាបឋមសិក្សាអាចចែកចាយកញ្ចប់ព័ត៌មានចុះឈ្មោះដល់គ្រួសារដែលបម្រុងចុះឈ្មោះនាពេលអនាគត និងសហគមន៍របស់ពួកគេ។ |
| **ចាប់ពីសប្តាហ៍ទី1 ត្រីមាសទី2 ឆ្នាំ2023** | **ការបើកទទួលពាក្យសុំចុះឈ្មោះសុំចូលរៀន** – ឪពុកម្តាយ/អ្នកថែទាំ អាចដាក់ពាក្យសុំចុះឈ្មោះចូលរៀនដែលបានបំពេញរួចរាល់ទៅសាលាបឋមសិក្សារបស់រដ្ឋ ចាប់ពីកាលបរិច្ឆេទនេះ។ |
| **ត្រីមាសទី3៖ នៅថ្ងៃចន្ទ ទី10 ខែកក្កដា ឆ្នាំ2023 និងថ្ងៃសុក្រ ទី15 ខែកញ្ញា ឆ្នាំ2023** | |
| **ត្រឹមថ្ងៃសុក្រ ទី28 ខែកក្កដា ឆ្នាំ2023** | **កាលកំណត់ពាក្យសុំចុះឈ្មោះចូលរៀន** – ការបិទទទួលពាក្យសុំចុះឈ្មោះចូលរៀន ឪពុកម្តាយ/អ្នកថែទាំ ដាក់ពាក្យសុំចុះឈ្មោះចូលរៀនដែលបានបំពេញរួចរាល់ទៅសាលាបឋមសិក្សារបស់រដ្ឋត្រឹមកាលបរិច្ឆេទនេះ។ |
| **ត្រឹមថ្ងៃសុក្រ ទី11 ខែសីហា ឆ្នាំ2023** | សាលាបឋមសិក្សានឹងជូនដំណឹងដល់ឪពុកម្តាយ/អ្នកថែទាំជាលាយលក្ខណ៍អក្សរ អំពីលទ្ធផលចុះឈ្មោះចូលរៀនថ្នាក់មូលដ្ឋាន(ថ្នាក់ត្រៀម) ស្របតាម 'លំដាប់អាទិភាពនៃការទទួលសិស្សចូលរៀន' ក្រោមគោលការណ៍ទទួលសិស្សចូលរៀនរបស់ក្រសួង។ នេះរួមអាចមានលិខិតបញ្ជាក់ការចុះឈ្មោះ លិខិតទទួលចូលរៀន ឬលិខិតបដិសេធចូលរៀន។<br>ឪពុកម្តាយ/អ្នកថែទាំដែលទទួលបានលិខិតបដិសេធចូលរៀន អាចចាប់ផ្តើមដាក់ពាក្យបណ្តឹងតវ៉ាជាលាយលក្ខណ៍អក្សរចំពោះការបដិសេធចូលរៀននេះ ទៅសាលាបឋមសិក្សាដែលពួកគេពេញចិត្ត។ |

| | |
|---|---|
| **ត្រឹមថ្ងៃសុក្រ ទី25 ខែសីហា ឆ្នាំ2023** | ឪពុកម្តាយ/អ្នកថែទាំដែលបានទទួលលិខិតអនុញ្ញាតចូលរៀន ត្រូវបង្ហាញការយល់ព្រមនូវការទទួលចូលរៀនរបស់កូនពួកគេ ត្រឹមកាលបរិច្ឆេទនេះ។ |
| **ត្រឹមថ្ងៃសុក្រ ទី25 ខែសីហា ឆ្នាំ2023** | **កាលបរិច្ឆេទបិទ** សម្រាប់ឪពុកម្តាយ/អ្នកថែទាំ ដើម្បីដាក់បណ្តឹងតវ៉ាជាលាយលក្ខណ៍អក្សរ ចំពោះការបដិសេធចូលរៀនក្នុងសាលាបឋមសិក្សាដែលពួកគេពេញចិត្ត។ |
| **ត្រឹមថ្ងៃសុក្រ ទី15 ខែកញ្ញា ឆ្នាំ2023** | សាលាបឋមសិក្សាជូនដំណឹងដល់ឪពុកម្តាយ/អ្នកថែទាំទាំងអស់ ជាលាយលក្ខណ៍អក្សរអំពី លទ្ធផលនៃបណ្តឹងឧទ្ធរណ៍ចំពោះការបដិសេធចូលរៀនរបស់ពួកគេត្រឹមកាលបរិច្ឆេទនេះ។ |
| **ត្រីមាសទី4៖ ថ្ងៃចន្ទ ទី02 ខែតុលា ឆ្នាំ2023 ដល់ថ្ងៃពុធ ទី20 ខែធ្នូ ឆ្នាំ2023** | |
| **ក្នុងអំឡុងត្រីមាសទី4 ឆ្នាំ2023** | សាលាបឋមសិក្សានឹងរៀបចំវគ្គស្តីពីការផ្ទេរអន្តរកម្ម។ |
| **ត្រឹមថ្ងៃសុក្រ ទី20 ខែតុលា ឆ្នាំ2023** | **កាលបរិច្ឆេទបិទ** សម្រាប់ឪពុកម្តាយ/អ្នកថែទាំដើម្បីដាក់បណ្តឹងឧទ្ធរណ៍ជាលាយលក្ខណ៍អក្សរចំពោះការបដិសេធចូលរៀន ជាមួយនាយកតំបន់ភូមិភាគពាក់ព័ន្ធ ប្រសិនបើពួកគេមិនបានទទួលជោគជ័យក្នុងបណ្តឹងឧទ្ធរណ៍របស់ពួកគេ ជាមួយសាលាបឋមសិក្សាដែលពួកគេពេញចិត្ត។ |
| **ត្រឹមថ្ងៃសុក្រ ទី17 ខែវិច្ឆិកា ឆ្នាំ2023** | តំបន់ភូមិភាគជូនដំណឹងដល់ឪពុកម្តាយ/អ្នកថែទាំទាំងអស់ជាលាយលក្ខណ៍អក្សរ អំពីលទ្ធផលនៃសេចក្តីសម្រេចរបស់នាយកប្រចាំតំបន់ភូមិភាគ លើបណ្តឹងឧទ្ធរណ៍ចំពោះការបដិសេធចូលរៀនត្រឹមកាលបរិច្ឆេទនេះ។ នេះអនុវត្តចំពោះតែបណ្តឹងឧទ្ធរណ៍ដែលបានទទួលត្រឹមកាលបរិច្ឆេទបិទនៅថ្ងៃសុក្រ ទី20 ខែតុលា ឆ្នាំ2023ប៉ុណ្ណោះ។ |